នស/រកត/០២២០/១៩៨

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១..**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួនបីដូចខាងក្រោម៖

-សាលាឧទ្ធរណ៍ព្រះសីហនុ

-សាលាឧទ្ធរណ៍បាត់ដំបង

-សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

សាលាឧទ្ធរណ៍តំបន់ទាំងបីនេះ ចាប់ផ្តើមដំណើរការពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ នេះតទៅ។

នៅអមសាលាឧទ្ធរណ៍តំបន់នីមួយៗ មានមហាអយ្យការមួយ ស្របតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត។

**មាត្រា ២.-**

សាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងស្ថិតនៅក្នុងខេត្តបាត់ដំបង និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំងស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍ភ្នំពេញ មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍តំបន់ លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ តទៅ។

ចំពោះសំណុំរឿងទាំងឡាយដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់សាលាឧទ្ធរណ៍តំបន់ ប៉ុន្តែដែលសាលាឧទ្ធរណ៍ភ្នំពេញបានទទួលជាសមត្ថកិច្ច នៅមុនថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ត្រូវកំណត់ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីបាត់ការបន្ត ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

វិធានដែលមានចែងក្នុងមាត្រានេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់។

**មាត្រា ៤.-**

ក្នុងករណីដែលសាលាឧទ្ធរណ៍តំបន់ណាមួយមិនអាចដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចេញប្រកាស ដើម្បីកំណត់អំពីការមិនអាចដំណើរការបាននៃសាលាឧទ្ធរណ៍

តំបន់នេះ។

ប្រសិនបើសាលាឧទ្ធរណ៍តំបន់ណាមួយមានចៅក្រមមិនគ្រប់គ្រាន់ ឬខ្វះខាតចៅក្រមដោយមូលហេតុវិសមិតភាពជាអាទិ៍ ប្រធានសាលាឧទ្ធរណ៍តំបន់នោះត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់តាំងចៅក្រមពីសាលាឧទ្ធរណ៍ផ្សេងទៀតមកបំពេញសមាសភាព។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ និងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយព្រះរាជក្រឹត្យនេះ។

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

១៧៣.២០០២.២០៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**